NSW GOVERNMENT
Department of Primary Industries
primefact

ការគ្រប់គ្រងដង្កូវស៊ីញ៉ៅស្លឹកបត់ចុះបត់ឡើង

ខែធ្នូ ឆ្នាំ 2020, Primefact PUB20/933 បោះពុម្ពលើកទី១

Sylvia Jelinek, Jonathan Eccles សេរ៉ាកម្មដ៏ធ្ងឺក្នុងតំបន់ ស៊ីដនីយ

ដង្កូវស៊ីញ៉ៅស្លឹកបត់ចុះបត់ឡើង

ដង្កូវស៊ីញ៉ៅស្លឹកបត់ចុះបត់ឡើង (*Liriomyza huidobrensis)*
ត្រូវបានគេរកឃើញនៅលើដំណាំបន្លែនៅ Sydney Basin (តំបន់ជម្រាលស៊ីដនីយ) ក្នុងខែតុលា ឆ្នាំ 2020។
គេមិនបានរកឃើញវានៅក្នុងប្រទេសអូស្ត្រាលី ពីមុនៗទេ
ហើយត្រូវបានចាត់ទុកថាជាសត្វល្អិតរុក្ខជាតិដែល
ត្រូវចាត់វិធានការបន្ទាន់នៅក្នុងប្រទេសអូស្ត្រាលី។
វាត្រូវបាន គេរកឃើញនៅរដ្ឋឃ្វីនស្លែនប៉ែកខាងត្បូង។

ដង្កូវស៊ីញ៉ៅស្លឹកបត់ចុះបត់ឡើង (SLM)
ជាប្រភេទសត្វល្អិត ចង្រៃមួយនៅជុំវិញពិភពលោក
ដែលប៉ះពាល់យ៉ាងខ្លាំងដល់ ឧស្សាហកម្មសាកវប្បកម្ម។

វាជារុយខ្មៅតូចមួយដែលស៊ី
ហើយពងដាក់លើស្លឹករុក្ខជាតិ។
នៅពេលដែលកូនដង្កូវញាស់ វា “ខួង”
កាត់ចូលទៅខាងក្នុង ស្លឹក
ហើយបន្សល់ទុកនូវផ្លូវបត់ចុះបត់ឡើង ដែលអាចមើលឃើញដោយភ្នែកទទេ។

កម្រិតខ្ពស់នៃការរាលដាលកូនដង្កូវ
ប៉ះពាល់ដល់សមត្ថភាព
របស់រុក្ខជាតិក្នុងការធ្វើរស្មីសំយោគ
កាត់បន្ថយការលូតលាស់ របស់រុក្ខជាតិ
និងទិន្នផលដំណាំ។

SLM ភ្ជាយជាងុកងឿនៅផ្នែកខាងក្រោមនៃស្លឹក
(សំបុកនាង តូចពណ៌ស្មោកប្រវែង 1-3 មម)
ប៉ុន្តែវាអាចត្រូវបានប៉ះផ្លាក់ ទៅលើដីយ៉ាងងាយ
ឬធ្លាក់ចូលទៅក្នុងរន្ធបន្លែយកស្លឹក។

រុក្ខជាតិជម្រកនៃ SLM មានច្រើនប្រភេទ រួមមានបន្លែ
រុក្ខជាតិលម្អ
និងរុក្ខជាតិតូចៗឥតប្រយោជន៍ជាច្រើនប្រភេទ។
ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនៃសត្វល្អិតចង្រៃ
នេះ គឺពិបាកណាស់។

រូបភាពទី 1 ដង្កូវស៊ីញ៉ៅស្លឹកបត់ចុះបត់ឡើង (Liriomyza huidobrensis)

វិធីសាស្ត្រចម្រុះក្នុងការគ្រប់គ្រងសត្វល្អិតចង្រៃ

វិធីសាស្ត្រចម្រុះក្នុងការគ្រប់គ្រងសត្វល្អិតចង្រៃ (IPM)
ប្រកប ដោយប្រសិទ្ធភាព
គឺជាវិធីសាស្ត្រយៈពេលវែងដ៏ល្អបំផុតក្នុង ការគ្រប់គ្រង SLM។

IPM
ទាក់ទងនឹងការគ្រប់គ្រងសត្វល្អិតដោយប្រើបច្ចេកទេស
រួមផ្សំ ដូចជាការគ្រប់គ្រងដោយជីវសាស្ត្រ
ការកែប្រែមធ្យោបាយ ដំណាំ ការឃ្លាំមើលសត្វល្អិតចង្រៃ
និងការប្រើប្រាស់ថ្នាំសម្លាប់
សត្វល្អិតតាមបែបមិត្តភាពដែលមិនប្រឆាំងនឹង IPM។

នៅតាមបណ្តាប្រទេសក្រៅជាច្រើន
ការពឹងផ្អែកច្រើនលើស
លប់លើការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត
បាននាំឱ្យមានការ កើនឡើងនូវភាពធន់ទ្រាំនៅក្នុង
IPM ដែលនាំឱ្យមានការ
កើនឡើងនូវកម្រិតនៃការបំផ្លាញរុក្ខជាតិ
ដោយសារសម្ពាធ សត្វល្អិតចូន។
ការប្រើប្រាស់គីមីសំដៅទៅលើប្រភេទសត្វល្អិត ដទៃទៀត
ជាពិសេសថ្នាំសម្លាប់សត្វល្អិតដែលមានវិសាលភាព
ទូលំទូលាយ អាចជ្រៀតជ្រែកដល់កម្មវិធី IPM
និងអាចនាំឱ្យ មានការផ្ទុះឡើងបន្ទាប់បន្សំនៃ SLM
ក្នុងករណីអវត្តមាននៃ សត្វព្រាដែលមានប្រយោជន៍។
ប្រសិនបើត្រូវប្រើសារធាតុគីមី ជាជម្រើសដើម្បីគ្រប់គ្រង

ការគ្រប់គ្រងដង្កូវស៊ីញ៉ៅស្លឹកបត់ចុះបត់ឡើង

ចូរជ្រើសរើសមួយណាដែលជាមិត្ត ភាពមិនប្រឆាំងនឹង IPM។។

មានប្រភេទពពួកឪម៉ាល់ជ៉ាវ៉ាស៊ីតកយមួយចំនួន ដែលកំណត់
គោលដៅសម្រាប់ដង្កូវស៊ីញ៉ៅស្លឹកបត់ចុះបត់ឡើងរួចហើយនៅ ក្នុងប្រទេសអូស្ត្រាលី
ហើយផ្តល់នូវជម្រើសត្រួតពិនិត្យគ្មាន
សារធាតុគីមីដែលមានប្រសិទ្ធភាព។

ឪម៉ាល់ជ៉ាវ៉ាស៊ីតកយ អាចចូលទៅដល់កូនដង្កូវ SLM នៅក្នុង ស្លឹក ហើយដាក់ពងរបស់វានៅលើ
ឬនៅក្នុងកូនដង្កូវ (រូបភាព ទី 2)។ ប្រព័ន្ធ IPM
ដែលគ្រប់គ្រងបានល្អ អាចឃើញអត្រា ដាប់នៃ SLM
មានដល់ទៅ 80 ភាគរយ។

មានឪម៉ាល់ជ៉ាវ៉ាស៊ីតកយជាង 50 ប្រភេទដែលកំណត់គោលដៅលើរុយដង្កូវស៊ីញ៉ៅស្លឹកបត់ចុះបត់ឡើង ទោះជាយ៉ាងណាក្តី
មានបួនប្រភេទដែលល្អក្នុងការកំណត់គោលដៅ SLM៖

- *Opius* spp.
- *Diglyphus isaea*
- *Hemiptarsenus varicornis*
- *Zagrammosoma latilineatum*

ការគ្រប់គ្រងការដាំដំណាំ

វិធីល្អបំផុតដើម្បីគ្រប់គ្រង SLM
គឺកាត់បន្ថយហានិភ័យនៃ
សត្វល្អិតចង្រៃចូលក្នុងទ្រព្យសម្បត្តិរបស់អ្នក។

- នៅកន្លែងណាដែលអាចធ្វើទៅបាន
  ទិញស្តុកដំណាំពី
  គម្រោងការទទួលស្គាល់ជាផ្លូវការនៃឧស្សាហកម្មបណ្តុះ កូនរុក្ខជាតិអូស្ត្រាលី (NIASA)
  អ្នកផ្គត់ផ្គង់ដែលមាន ការទទួលស្គាល់ជាផ្លូវការ។
  ប្រសិនបើទិញពីអ្នកផ្គត់ផ្គង់
  ដែលមិនមានការទទួលស្គាល់ជាផ្លូវការ
  សូមសួរកការ ផ្ទៀងផ្ទាត់ថា
  អាជីវកម្មមានផែនការគ្រប់គ្រងសត្វល្អិតចង្រៃជំងឺ
  និងរុក្ខជាតិតូចៗតតប្រយោជន៍គ្រប់គ្រាន់រួចស្រេចឬនៅ។

- ពិនិត្យស្តុកចូលទាំងអស់
  ដើម្បីរកសត្វល្អិតចង្រៃជំងឺ
  និងរុក្ខជាតិតូចៗតតប្រយោជន៍។
  បំបែកស្តុកថ្មីពីដំណាំ
  រហូតដល់វាត្រូវបានបញ្ជាក់ថាគ្មានរោគសញ្ញា SLM។

- គ្រប់គ្រងរុក្ខជាតិតូចៗតតប្រយោជន៍ដែលនៅជុំវិញ ដំណាំ និងសួនច្បារ
  ជាពិសេសដំណាំដែលត្រូវបាន
  គេស្គាល់ថារុក្ខជាតិជម្រកនៃ SLM។

- ពិនិត្យស្លឹករុក្ខជាតិជាទៀងទាត់
  ដើម្បីរកដង្កូវស៊ីញ៉ៅស្លឹក បត់ចុះបត់ឡើង។

- បន្ទាប់ពីប្រមូលផល
  ភ្ជួររាស់ដំណាំដែលនៅសល់ភ្លាមៗ ដើម្បីកប់សំណល់។

- ការដាក់គម្របបណ្តែតលើដំណាំដែលងាយរងផលប៉ះពាល់ អាចការពារសត្វរុយពីការដាក់ពង។

រូបភាពទី 2 ពពួកឪម៉ាល់ជ៉ាវ៉ាស៊ីតកយ Zagrammosoma latilineatum

- កម្រាល
  និងផ្លូវដើរនៅក្នុងផ្ទះកញ្ចក់គួរតែបានរចនាឡើងដើម្បីការពារសត្វរុយក្លាយជាដុកដៀនៅក្នុងដី ។ ប្តាស្ទិចខ្មៅ ដាក់ក្រួស ឬបេតុងជម្រៅសរុប 75 មីលីម៉ែត្រ ជួយការពារការចម្លងរោគ
  និងធ្វើឱ្យអនាម័យ ទូទៅបានប្រសើរឡើង។

- យកចេញកាកសំណល់បៃតងទាំងអស់ ដូចជាជាង ឬម៉ែកកាត់ និងស្លឹកដែលនៅសេសសល់
  ហើយកប់វា។

- ទិញសម្ភារៈដែលបានវេចខ្ចប់ក្នុងថង់
  ពីអ្នកផ្គត់ផ្គង់ល្បី ឈ្មោះ។
  ទិញសម្ភារៈដែលនៅដាច់ពីគ្នា ពីអ្នកផ្គត់ផ្គង់
  មានការទទួលស្គាល់ជាផ្លូវការ NIASA
  មុនពេលប្រើ។

- បើដាំដំណាំតែមួយមុខ ពេលដាំដំណាំចប់
  ចូរបញ្ឈប់ការ ស្រោចស្រព
  ហើយបិទទ្វារផ្ទះដើម្បីបង្កើនសីតុណ្ហភាព
  ខាងក្នុង។ សីតុណ្ហភាពខ្ពស់
  គឺមានគ្រោះថ្នាក់បណ្តាល ឱ្យដាប់ដល់ SLM។

- គួរសម្អាតកន្លែងអង្គុយ និងផ្ទៃរឹង រវាងដំណាំ។

ការគ្រប់គ្រងផលដំណាំ

នៅតាមទ្រព្យសម្បត្តិដែលមានហានិភ័យ (អ្នកដែលដាំដុះរុក្ខជាតិជម្រកប្រភេទសត្វល្អិតចង្រៃ) ត្រូវតែគ្រប់គ្រង SLM យ៉ាងសកម្ម
នៅតាមបណ្តោយខ្សែសង្វាក់ផ្គត់ផ្គង់ទាំងមូល
ដើម្បីគ្រប់គ្រង SLM នៅក្នុងតំបន់ផលិតកម្ម។

ជម្រើសត្រួតពិនិត្យសម្រាប់ SLM
មិនបញ្ឈប់នៅដំណាំនោះ ទេ។
ការគ្រប់គ្រងហានិភ័យជីវសន្តិសុខនៃ SLM នៅក្នុងផលិតកម្មរុក្ខជាតិ
គឺជាផ្នែកមួយដ៏សំខាន់នៃកាតព្វកិច្ចជីវសន្តិសុខទូទៅរបស់យើងដើម្បីជានាថា SLM
មិនត្រូវបានដឹក
ជញ្ជូនដោយចៃដន្យទៅកាន់តំបន់ផលិតកម្មថ្មី។

ជាតុផ្សំនៃជីវិទ្យាសត្វល្អិក
អាចរាំងដល់កិច្ចខិតខំប្រឹងប្រែង គ្រប់គ្រង។ SLM
មានភាពធន់ទ្រាំនឹងសន្សើមកក ហើយអាច
រស់បានក្តៅសីតុណ្ហភាពធ្លាក់ចុះដល់ក្រោម 20°
អង្សាសេ
ហើយពងមានដំណាក់កាលជីវិតដែលធន់ទ្រាំបំផុត។
ការស្លក ទុកត្រជាក់ជាពិសេស
មិនមែនជាជម្រើសដ៏ល្អសម្រាប់បន្លែទេ
ដ្បិតអីសីតុណ្ហភាពទាបខ្លាំង
អាចបង្កគ្រោះថ្នាក់ដល់ផលិត ផល។

ជម្រើសសារធាតុគីមី

មានជម្រើសគ្រប់គ្រងដោយប្រើសារធាតុគីមីមួយចំនួន
សម្រាប់ SLM។ ទោះយ៉ាងណាក៏ដោយ
មានតែពីរបីប៉ុណ្ណោះដែលស៊ី គ្នាជាមួយនឹង IPM។

កូនដង្កូវដែលរស់នៅខាងក្នុងស្លឹក
ត្រូវបានការពារភាគច្រើនពី
ការបាញ់ថ្នាំសម្លាប់សត្វល្អិតតាមទម្លាប់។
ថ្នាំសម្លាប់សត្វល្អិត ពុលជ្រាបលើផ្ទៃទាំងមូល (systemic insecticides)
និងថ្នាំសម្លាប់សត្វល្អិតពុលជ្រាបក្នុងតំបន់ (translaminar insecticides)
គឺល្អប្រសើរព្រោះវាអាចជ្រាបទៅដល់ដង្កូវ។

ថ្នាំសម្លាប់សត្វល្អិតជាច្រើន
នឹងមានផលប៉ះពាល់អវិជ្ជមាន
ដល់សត្វពាដែលមានប្រយោជន៍ SLM
ដូចជាឌីម៉ាល់ប៉ារ៉ា ស៊ីតតយ។
កម្មវិធីបាញ់ថ្នាំមិនត្រឹមត្រូវ នឹងមានផលប៉ះពាល់
យ៉ាងធ្ងន់ធ្ងរដល់កម្មវិធី IPM
ហើយអាចនាំឱ្យមានការកើន ឡើងនៃចំនួន SLM។

ការជ្រើសរើសសារធាតុគីមី
និងការស្លាស់ថ្នាំសម្លាប់សត្វល្អិត
ពីក្រុមសារធាតុគីមីផ្សេងៗគ្នា
គឺមានសារៈសំខាន់ក្នុងការកាត់ បន្ថយហានិភ័យនៃ
SLM បង្កើតភាពធន់ទ្រាំនឹងថ្នាំសម្លាប់ សត្វល្អិត។ SLM
ត្រូវបានគេដឹងថាបង្កើតភាពធន់ទ្រាំទៅនឹង
សារធាតុគីមីជាច្រើននៅបរទេស
ហើយរបៀបនៃការធន់ទ្រាំ ខុសគ្នាពីប្រទេសមួយ
ទៅប្រទេសមួយដោយផ្អែកលើរបប ជាញ់ថ្នាំដែលប្រើ។

អង្គភាពការធន់ទ្រាំនឹងថ្នាំសម្លាប់សត្វល្អិតរបស់ NSW DPI កំពុងវាយតម្លៃហ្វូងនៃ SLM
នៅរដ្ឋញូវសៅវែលដើម្បីកំណត់
ថាតើភាពធន់ទ្រាំនឹងសារធាតុគីមីមានរួចហើយឬអត់។
ប្រសិន បើការនេះត្រូវបានរកឃើញ
អនុសាសន៍ត្រួតពិនិត្យសារធាតុ
គីមីនឹងត្រូវបានកែសម្រួលតាមនោះ។

បញ្ជីរាយឈ្មោះជម្រើសសារធាតុគីមីដែលបានចុះបញ្ជីទាន់
បច្ចុប្បន្នភាព
និងអាជ្ញាប័ណ្ណដែលមិនបានយល់ព្រមជាផ្លូវការ សម្រាប់
SLM អាចរកបាននៅតាមទំព័រ៊ុបសៃថ៍របស់ NSW DPI
ការគ្រប់គ្រងសារធាតុគីមីសម្រាប់ដង្កូវស៊ីញ៉ៀស្លឹកបត់ចុះបត់ឡើង
និងទំព័រ៊ុបសៃថ៍របស់បញ្ជីចុះឈ្មោះអាជ្ញាធរគ្រប់
គ្រងថ្នាំសម្លាប់សត្វល្អិត និងថ្នាំការពារជំងឺសត្វអូស្ត្រាលី
ហើយនិងអាជ្ញាប័ណ្ណ។

កាតព្វកិច្ចជីវសន្តិសុខទូទៅ

ផ្នែកទី 3 នៃ*ច្បាប់ជីវសន្តិសុខ* (ឆ្នាំ 2015) ពិពណ៌នាអំពី
ពេលណាអ្នកមានកាតព្វកិច្ចជីវសន្តិសុខទូទៅ
ដើម្បីការពារ លុបបំបាត់
ឬកាត់បន្ថយហានិភ័យនៃដង្កូវស៊ីញ៉ៀស្លឹកបត់ចុះ
បត់ឡើងក្នុងរដ្ឋញូវសៅវែល។

អ្នកដែលទាក់ទងនឹងរុក្ខជាតិជម្រកនៃ SLM
ដែលឃើញមាន សញ្ញានៃការខូចខាតស្លឹក
ដោយដង្កូវស៊ីញ៉ៀស្លឹកបត់ចុះបត់ ឡើង
ត្រូវតែចាត់វិធានការដើម្បីជានាថាពួកគេកំពុងបំពេញ
កាតព្វកិច្ចជីវសន្តិសុខទូទៅនេះ។ ឱ្យងាយយល់
អ្នកត្រូវតែ ចាត់វិធានការដានិច្ច
ដើម្បីការពារការឆ្លងរាលដាលនៃ SLM
យ៉ាងច្រើនក្នុងរដ្ឋញូវសៅវែល
បំបាត់ចោលការរាលដាលនៃ សត្វល្អិតចង្រៃ
និងកាត់បន្ថយផលប៉ះពាល់នៃ SLM នៅក្នុង
ប្រព័ន្ធផលិតកូនរុក្ខជាតិ។

កាតព្វកិច្ចនេះ
អាចត្រូវបានបំពេញដោយមធ្យោបាយណាមួយ
ដែលត្រូវបានចាត់ទុកថា
ជាការអនុវត្តការគ្រប់គ្រងល្អបំផុត សម្រាប់ SLM
រួមមាន៖

- មិនលក់រុក្ខជាតិជម្រកដែលមានការរាលដាល SLM យ៉ាងច្រើន
- តាមរយៈការប្រើប្រាស់នៃ IPM
  ដើម្បីកាត់បន្ថយផល ប៉ះពាល់នៃ SLM
  នៅក្នុងប្រព័ន្ធផលិតកម្ម
- ការប្រកាន់ខ្ជាប់នូវស្តង់ដាឧស្សាហកម្ម ដូចជា Biosecure HACCP
  ឬការរៀបចំការចូលទៅកាន់ ទីផ្សារដូចជា ICA29។
- ការព្យាបាលរុក្ខជាតិជម្រក
  ជាមួយថ្នាំសម្លាប់សត្វល្អិត
  ការបាញ់ថ្នាំសម្លាប់មេរោគសត្វល្អិត ឬការព្យាបាល
  ដោយប្រើកាំរស្មីដែលបានយល់ព្រម
  ដើម្បីការពារការរីក រាលដាលនៃផលិតផលជម្រក។

កាតព្វកិច្ចជីវសន្តិសុខទូទៅ
គឺជាយន្តការនីតិប្បញ្ញត្តិដោយសារ
ហានិភ័យនៃផលប៉ះពាល់អវិជ្ជមានដល់សេដ្ឋកិច្ច
និងសហ គមន៍ដែលកើតឡើងពីវត្តមាន
ការឆ្លងរាលដាល ឬការកើន
ឡើងនៃដង្កូវស៊ីញ៉ៀស្លឹកបត់ចុះបត់ឡើង
នៅរដ្ឋញូវសៅវែល។

សេចក្តីថ្លែងអំណរគុណ

រូបភាពទី 1 របស់ Merle Shepard, Gerald R.Carner, និង P.A.C Ooi សត្វល្អិត និងសត្រូវធម្មជាតិរបស់ពួកវា

ការគ្រប់គ្រងដង្កូវស៊ីញ៉ៀស្លឹកបត់ចុះបត់ឡើង

ទាក់ទិននឹងបន្លែ និងសណ្តែកនៅអាស៊ីអាគ្នេយ៍
Bugwood.org

រូបភាពទី 2 របស់វេជ្ជបណ្ឌិត Dr Elia Pirtle, Cesar

ការគ្រប់គ្រងដង្កូវស៊ុយ៉ៅស្លឹកបត់ចុះបត់ឡើង

PUB20/933

© រដ្ឋញូវសៅវែល តាមរយៈ Regional NSW 2021។
ព័ត៌មានដែលមានចុះនៅក្តងការបោះពុម្ពផ្សាយនេះ
គឺផ្អែកលើចំណេះដឹង និងការយល់ដឹងនៅពេលសរសេរ (ខែធ្នូ ឆ្នាំ 2020)។
ទោះយ៉ាងណាក៏ដោយ ដោយសារភាពងឿនលើនខាងចំណេះដឹង
អ្នកប្រើប្រាស់ត្រូវបានរម្លឹកអំពីភាព
ចាំបាច់ដើម្បីជានាថាព័ត៌មានដែលពួកគេពឹងផ្អែក គឺទាន់សម័យ
និងដើម្បី ពិនិត្យមើលភាពទាន់ពេលវេលានៃព័ត៌មាន
ជាមួយមន្ត្រីសមស្របរបស់ក្រសួង Regional NSW
ឬទីប្រឹក្សាឯករាជ្យរបស់អ្នកប្រើប្រាស់។